**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រធរាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងឯកឧត្តម **សួន ចាន់ថន** ជាមេធាវីរាជរដ្ឋាភិបាល មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧ស.០៥០៣.១១៨

ធ្វើទៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

លេខ ១០០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ០៣ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងឯកឧត្តម ជួន ឈឿង ជាមេធាវីរាជរដ្ឋាភិបាល មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៥០៣.១១៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

លេខៈ ១០២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

.//.

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១៧

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម សឿង ស៊ីម៉ុណា ជាអគ្គលេខាធិការរង នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស-០៥០៣.១២០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

លេខ ១០៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៣ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៧០ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការប្រកាសបន្តនីតិកាលទី ១ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៣/១៦៧ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងទីប្រឹក្សាផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១**: ត្រូវបានផ្ទេរភារកិច្ច ឯកឧត្តម **ជា សុខ** ពីនាយកខុទ្ទកាល័យសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា អោយទៅបំពេញមុខងារផ្សេង ដោយរក្សាមុខតំណែងជាទីប្រឹក្សាផ្ទាល់ របស់សម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា ២**: រាល់បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣**: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤**: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ... ១៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

៣រល.០៥០៣.១៧១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៤៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតសាកលវិទ្យាល័យជាតិគ្រប់គ្រង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាស ឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានា នូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

# ស ំ រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១..**

សាកលវិទ្យាល័យជាតិគ្រប់គ្រង អក្សរកាត់ "**ស.ជ.គ**" ត្រូវបានសំរេចឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២..**

**ស.ជ.គ** ជានីតិបុគ្គល និង មានស្វ័យភាពហិរញ្ញវត្ថុ ។ **ស.ជ.គ** មានអាស័យដ្ឋាននៅ ផ្លូវលេខ៩៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ៣..**

**ស.ជ.គ.** មានភារកិច្ចជាអាទិ៍ ដូចតទៅ ÷

- បណ្តុះបណ្តាលអ្នកជំនាញឯកទេស រយៈពេលខ្លី និង ឧត្តមសិក្សាគ្រប់កំរិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ ធ្វើវិក្រិតការអ្នកបច្ចេកទេស បង្កើនទាំងបរិមាណ និងគុណភាព ស្របតាមសំណូមពរនៃសេចក្តីត្រូវការទូទាំងព្រះរាជាណាចក្រកម្ពុជា និង រៀបចំបើកសិក្ខាសាលា សន្និសីទផ្សេង ៗ តាមសំណូមពរចាំបាច់របស់សង្គម ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សំរាប់ **ស.ជ.គ** ។
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតំរូវការទីផ្សារការងារ និង ស្តង់ដាអន្តរជាតិ ។
- សិក្សាស្រាវជ្រាវខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន និង ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិ និង ភាសាបរទេស ឱ្យបានសមស្របសំរាប់ប្រើប្រាស់ ។
- រៀបចំ និង ដំណើរការ ជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រលងចេញ និងស្វ័យវាយតំលៃការសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និង ប្រកបដោយតម្លាភាព ។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងឯកទេសរបស់សាកលវិទ្យាល័យ ។
- កសាងផែនការអភិវឌ្ឍន៍សំរាប់ **ស.ជ.គ** ។
- គ្រប់គ្រងមន្ត្រីរាជការ និយោជិត កម្មករ និស្សិត សាស្ត្រាចារ្យ និង ទ្រព្យសម្បត្តិរបស់ **ស.ជ.គ** ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័ននានា ក្នុងគោលបំណង ធ្វើឱ្យកាន់តែល្អប្រសើរនូវការសិក្សា ការបង្រៀន និង ការស្រាវជ្រាវ ។

## ជំពូក ២

## រដ្ឋបាល និង ការគ្រប់គ្រង

## ផ្នែកទី ១

## ក្រុមប្រឹក្សាភិបាល

**មាត្រា ៤..**

**ស.ជ.គ** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារ ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ និង បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានការយល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរ ។

**មាត្រា ៥..**

៥.១.. ក្រុមប្រឹក្សាភិបាលមានសមាជិក ០៥ រូប ដែលមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១- តំណាងក្រសួងអប់រំយុវជន និង កីឡា | ១ រូប សមាជិក |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប សមាជិក |
| ៣- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប សមាជិក |
| ៤- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង | ១ រូប ជាសមាជិកស្វ័យប្រវត្តិ |
| ៥- តំណាងបុគ្គលិកនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង | ១រូប ជាសមាជិកស្វ័យប្រវត្តិ |

៥.២.. តំណាងបុគ្គលិកសាកលវិទ្យាល័យជាតិគ្រប់គ្រង ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ស.ជ.គ** ។

៥.៣.. ប្រធាន និង សមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើ នៃក្រសួង ឬ ស្ថាប័នដែលខ្លួនតំណាងឱ្យ ។

**មាត្រា ៦..**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារ យ៉ាងតិច ៥ ( ប្រាំ ) ឆ្នាំ មានអាយុមិនលើសពី ៦៥ ឆ្នាំ មានបទពិសោធន៍គ្រប់គ្រាន់ និង មានចំណេះដឹងខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច អប់រំឧត្តមសិក្សា ឬនីតិសាស្ត្រដែលមានសញ្ញាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មក្រិតធ្ងន់ពីតុលាការឡើយ ។

**មាត្រា ៧..**

**៧.១..** ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និង កំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុម - ប្រឹក្សាភិបាល ។

**៧.២..** ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើផ្នែកឧត្តមសិក្សា ឬ តំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់យោបល់ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា ៨..**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំតំរង់ទិសដៅ និង ធ្វើការត្រួតពិនិត្យលើដំណើរការរបស់សាកល-វិទ្យាល័យ ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាល ត្រូវ ÷

- ពិនិត្យ និង សម្រេចលើផែនការអភិវឌ្ឍន៍នៃ **ស.ជ.គ** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និង សម្រេចលើចំណូល និង ចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ស.ជ.គ**
- ពិនិត្យ និង សម្រេចលើ របាយការណ៍គ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និង ភារកិច្ចទូទៅ ដល់អង្គភាពក្រោមឱវាទ
- កំណត់បែបបទ នៃការជ្រើសរើស ការតំលើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ស.ជ.គ** ដោយ មិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ ឬ បទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះភ្នាក់ងារមុខងារ-សាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសំរាប់ **ស.ជ.គ**
- សម្រេចលើកិច្ចសន្យា ស្តីពីលទ្ធកម្ម
- កំណត់បទបញ្ជាផ្ទៃក្នុងនៃ **ស.ជ.គ**
- ធ្វើការវាយតំលៃ តាមចន្លោះពេលទៀងទាត់ លើកំរិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ស.ជ.គ** ហើយកំណត់វិធានការកែតំរូវដើម្បីអនុវត្ត ។

**មាត្រា ៩..**

**៩.១..** លាភការរបស់សមាជិកនៃក្រុមប្រឹក្សាភិបាល និង ប្រាក់បំណាច់របស់សាកលវិទ្យាធិការត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា តាមសំណើរបស់ក្រុមប្រឹក្សា-ភិបាល។

**៩.២..** លាភការ ឬប្រាក់បំណាច់ខាងលើ អាចត្រូវបញ្ឈប់ចំពោះសមាជិកណាម្នាក់ នៃក្រុមប្រឹក្សាភិបាល ដែលមិនមកបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១០..**

១០.១.. ក្រុមប្រឹក្សាភិបាល នៃ **ស.ជ.គ** ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ ប្រធាន ឬតាមការស្នើរបស់សមាជិកចំនួន២/៣(ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំពីសាកលវិទ្យាធិការ នៃ **ស.ជ.គ** ។ ក្នុងករណី ប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ ដែលមានវ័យច្រើនជាងគេក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ តែមិនអាចជ្រើសរើសសមាជិកស្វ័យប្រវត្តិទេ ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ១ (មួយ) រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះ គ្មានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈ និងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ ។

១០.២.. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមានចំនួនលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូនតំណាង ឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសំឡេងកូរ៉ុមមិនគ្រប់ចំនួន ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំ ម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តំរូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំ លើកទីមួយ ។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខា លើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាន ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព ។

១០.៣.. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ និងដំកល់ទុកនៅទី - ស្នាក់ការរបស់ **ស.ជ.គ** និងត្រូវចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះត្រូវបង្ហាញអត្ថន័យ នៃការពិភាក្សាឱ្យបានច្បាស់លាស់ និង ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និង ផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០(ដប់) ថ្ងៃ ក្រោយពេលប្រជុំ ។

១០.៤.. **ស.ជ.គ** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ :

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍របស់សាកលវិទ្យាល័យ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍គ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥.. ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃឡើយ ។

## ផ្នែកទី ២
## អង្គការប្រតិបត្តិរបស់សាកលវិទ្យាល័យ

**មាត្រា ១១..**

**ស.ជ.គ** ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការផ្ដល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ សាកលវិទ្យា-ធិការនេះ មានតួនាទី ជានាយកប្រតិបត្តិ ។

**មាត្រា ១២..**

១២.១.. សាកលវិទ្យាធិការនៃ **ស.ជ.គ** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និង អនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និង អនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

សាកលវិទ្យាធិការមានភារកិច្ច ÷

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍ **ស.ជ.គ** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ទទួលបន្ទុកអនុវត្ត សេចក្ដីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល និង ដាក់ឱ្យដំណើរការ នូវគោលនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ស.ជ.គ** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យសម្រេច
- ធ្វើរបាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និង រាល់សកម្មភាពផ្សេងទៀត ហើយដាក់ឯកសារទាំងនេះ ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ស.ជ.គ** ក្នុងក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្ដីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទី តាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់ **ស.ជ.គ**
- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមតាម សេចក្ដី-សម្រេច របស់ក្រុមប្រឹក្សាភិបាល ស្ដីពីការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិ ដទៃទៀត ស្ដីពីបញ្ហានេះ
- ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និង គ្រប់គ្រងការងារទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យតាមបទបញ្ជាផ្ទៃក្នុងរបស់ **ស.ជ.គ** និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២.. សាកលវិទ្យាធិការ នៃ **ស.ជ.គ** ជាតំណាងរបស់សាកលវិទ្យាល័យក្នុងទំនាក់ទំនងជាមួយតតិយជន។

១២.៣.. សាកលវិទ្យាល័យជាតិគ្រប់គ្រង មានរចនាសម្ព័ន្ធ ដូចតទៅ :

**ក- មហាវិទ្យាល័យ ខ- សាលាក្រោយឧត្តម គ- សាខា ខេត្ត-ក្រុង**

**ឃ-ផ្នែកសិក្សា ស្រាវជ្រាវ និង ផ្សព្វផ្សាយ ង- ផ្នែកគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញកិច្ច**

១២.៤..ព្រឹទ្ធបុរសមហាវិទ្យាល័យ នាយកសាលាក្រោយឧត្តម នាយកគ្រប់គ្រងសាខា នាយផ្នែក មានឋានៈស្មើ ប្រធាននាយកដ្ឋាន តែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា និងតាមយោបល់ របស់ ក្រុមប្រឹក្សាភិបាល ។

១២.៥..មហាវិទ្យាល័យ សាលាក្រោយឧត្តម សាខា ខេត្ត-ក្រុង និងផ្នែក មានព្រឹទ្ធបុរសរង នាយករងនិងនាយផ្នែករង មួយចំនួនជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ។

## ជំពូកទី ៣

## បុគ្គលិករបស់ " ស.ជ.គ "

**<u>មាត្រា ១៣</u> :**

១៣ .១ -បុគ្គលិកអចិន្ត្រៃយ៍របស់ **ស.ជ.គ** រួមមានមន្ត្រីរាជការក្របខ័ណ្ឌ មុខងារសាធារណៈ មកពីក្រសួងអប់រំយុវជន និង កីឡា ឬ ជ្រើសរើសតាមសំណើរបស់សាកលវិទ្យាធិការ នៃ **ស.ជ.គ** ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារ សាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

១៣ . ២- សាកលវិទ្យាល័យ អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យា ជំនួយការ និង បុគ្គលិកអណ្តែត ។ ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ ស្តីពីការងារ ។

១៣ . ៣ -បុគ្គលិក **ស.ជ.គ** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជា ស្តីពីបុគ្គលិកសម្រេចដោយក្រុមប្រឹក្សាភិបាល ។ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កំរៃលើកទឹកចិត្ត ចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៤

## ទ្រព្យសម្បត្តិរបស់ " ស.ជ.គ "

**<u>មាត្រា១៤</u> :**

១៤.១ ~ **ស.ជ.គ** ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :

-ដីជាទីតាំងសាកលវិទ្យាល័យជាតិ គ្រប់គ្រង ស្ថិតនៅផ្លូវលេខ៩៦ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញរាជធានីភ្នំពេញ មានផ្ទៃដី ៧.៨០៣ ម$^{2}$ ។

១៤ . ២ - ក្រៅពីអចលនទ្រព្យខាងលើ **ស.ជ.គ** ត្រូវបានទទួលនូវចលនទ្រព្យនិងអចលនទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣.. អចលនទ្រព្យ និង ចលនទ្រព្យ របស់ **ស.ជ.គ** មានចែងលំអិតក្នុងបញ្ជីសារពើភណ្ឌ ។

១៤.៤.. **ស.ជ.គ** អាចទិញ លក់ចលនទ្រព្យ និង ទិញអចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់ខ្លួន។

## ជំពូកទី ៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ " ស.ជ.គ "

**មាត្រា ១៥..**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ **ស.ជ.គ**ត្រូវប្រព្រឹត្តស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ៨២អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ឬកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៦..**

១៦.១.. សាកលវិទ្យាធិការ នៃ **ស.ជ.គ** ជាអាណាប័កដើមខ្សែរបស់សាកលវិទ្យាល័យ ហើយត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និង ទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និង ចេញបញ្ជាចំណាយ

១៦.២.. អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិ ឱ្យអាណាប័កផ្ទេរសិទ្ធិ ឬ អាចបង្កើតរជ្ជទេយ្យចំណូល ឬបុរេប្រទានបានដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា ១៧..**

១៧.១.. ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង របស់ **ស.ជ.គ** ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវទទួលខុសត្រូវចំពោះមុខសាកលវិទ្យាធិការ នៃ **ស.ជ.គ** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែពុំមានសិទ្ធិបោះឆ្នោតឡើយ ។

១៧.២.. ភ្នាក់ងារគណនេយ្យមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ

- រក្សាទុក និង ចាត់ចែងប្រើប្រាស់មូលនិធិ និង ធនធានរបស់សាកលវិទ្យាល័យ
- រក្សាទុកលិខិតយុត្តិការ និង កាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣.. ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការរបស់ខ្លួន ។

**មាត្រា ១៨..**

១៨.១.. ប្រភពធនធានរបស់ **ស.ជ.គ** រួមមាន ÷

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់ **ស.ជ.គ** នៅពេលបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និង ឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និង អច្ច័យទាន ដែល **ស.ជ.គ** បានទទួល
- ប្រាក់ខ្ចីបុល ដោយសាកលវិទ្យាល័យផ្ទាល់ និង ប្រាក់ ដែលរដ្ឋខ្ចីបុលឱ្យ **ស.ជ.គ**
- ផលការងារ និង កំរៃនៃការផ្តល់សេវាផ្សេងៗ ដោយ **ស.ជ.គ**
- កំរៃនៃទ្រព្យសម្បត្តិរបស់ **ស.ជ.គ** និង ចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាត ពីរាជរដ្ឋាភិបាល
- កំរៃនៃទ្រព្យសម្បត្តិ ដែលបានប្រគល់ឱ្យ **ស.ជ.គ** ។

១៨.២.. ចំណូលចំណាយ ជាប្រចាំព្រមទាំងមូលធន របស់ **ស.ជ.គ** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ។ ក្រុមប្រឹក្សាភិបាលរបស់ **ស.ជ.គ** ត្រូវចែងអំពីបែបបទ នៃការរៀបចំការចាត់ចែង និង អនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ដែលទាក់ទងដល់ទំរង់បែបបទ នៃការរៀបចំការចាត់ចែង និង អនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣.. អាណាប័កដើមខ្សែនៃ **ស.ជ.គ** ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ដោយមានបញ្ចូលទាំងគំរោងថវិកាលំអិតសំរាប់ឆ្នាំនីមួយៗ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែកញ្ញា នៃឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និង ចំណាយ ។

១៨.៤.. ក្នុងការរៀបចំថវិកាប្រចាំឆ្នាំសំរាប់ **ស.ជ.គ** អាណាប័កដើមខ្សែ ត្រូវរាប់បញ្ចូលថវិកា ដែលឧបត្ថម្ភ ដោយរាជរដ្ឋាភិបាល ។ ថវិកាឧបត្ថម្ភនេះ ត្រូវផ្តល់ឱ្យ **ស.ជ.គ** ដោយអនុលោមតាមមាត្រា ៥១ និង៥២ នៃព្រះរាជក្រឹត្យ លេខនស-រកត-០៣០៣-១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**មាត្រា ១៩..**

១៩.១.. ការងារគណនេយ្យរបស់ **ស.ជ.គ** រួមមាន ÷

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និង ប្រតិបត្តិការ ដែលអនុវត្តជាមួយតតិយជន

- គណនេយ្យ អសង្ហារឹម រូបធាតុ និង គណនេយ្យតំលៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់ ។

គណនេយ្យរបស់សាកលវិទ្យាល័យត្រូវ ÷

១- ស្របតាមវិធាន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២- គោរពតាមប្លង់គណនេយ្យរបស់ **ស.ជ.គ** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ប្លង់គណនេយ្យនេះ ត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**១៩.២..** គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ និង អាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២០..**

មូលនិធិរបស់ **ស.ជ.គ** គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៦
## របបសារពើពន្ធនៃ " ស.ជ.គ "

**មាត្រា ២១..**

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ **ស.ជ.គ** ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

## ជំពូកទី ៧
## លទ្ធកម្មរបស់ " ស.ជ.គ "

**មាត្រា ២២..**

ការសម្រេច ការអនុវត្ត និង ការត្រួតពិនិត្យ លើលទ្ធកម្មរបស់ **ស.ជ.គ** ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិនៃអនុក្រឹត្យ លេខ ៦០ អនក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និង បទបញ្ជាដទៃទៀតពាក់ព័ន្ធនឹងបញ្ហានេះ ។

## ជំពូក ៣
## អាណាព្យាបាល
## ផ្នែកទី ១ អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣.-**

**២៣.១.-** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ជ.គ** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និង គម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មានពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយសាកលវិទ្យាធិការ ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

**២៣.២.-** លិខិតយល់ព្រមត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬ តំណាង ហើយត្រូវ ផ្ញើជូនទៅសាកលវិទ្យាធិការ នៃ **ស.ជ.គ** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ សាកលវិទ្យាធិការ នៃ **ស.ជ.គ** ត្រូវបញ្ជូនពត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណី ដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬ គម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬ គម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍នៃ **ស.ជ.គ** និង ថវិកាចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេល ដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤.-**

**២៤.១.-** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចមានយោបល់ជំទាស់លើឯកសារដែលត្រូវបានបញ្ជូនមកខ្លួន ដូចមានចែងក្នុងមាត្រា១០ ខាងលើ ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងការជំទាស់ទាំងអស់នេះ ។

**២៤.២.-** សាកលវិទ្យាធិការនៃ **ស.ជ.គ** ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារ នៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរិះរកមធ្យោបាយសម្រាប់ ដោះស្រាយការជំទាស់ទាំងនេះ ។ ប្រសិនបើ ក្រុមប្រឹក្សាភិបាល សម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់

ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ស្ដីពីបញ្ហានេះ ជាលាយលក្ខណ៍អក្សរ ដល់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២៥..**

**២៥.១..** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចលុប ឬ ផ្អាកទុកសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា-ភិបាល ឬ សាកលវិទ្យាធិការ នៃ **ស.ជ.គ** ក្នុងករណីដែលសេចក្ដីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់សាកលវិទ្យាល័យ
- ផ្ទុយនឹងច្បាប់ និង បទបញ្ជា
- ធ្វើផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

**២៥.២..** ការលុបចោល ឬ ការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយមានបញ្ជាក់ពីមូលហេតុ តាមគំនិតផ្ទាល់ខ្លួន ឬ តាមបណ្ដឹងពីភាគីនានា ដែលពាក់ព័ន្ធ ។ ការលុបចោល ឬ ការផ្អាកទុកសេចក្ដីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់សាកលវិទ្យាធិការ នៃ **ស.ជ.គ** ហើយសាកលវិទ្យាធិការ ត្រូវជូនពត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦..**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចចាត់ឱ្យធ្វើអធិការកិច្ច ឬ ការត្រួតពិនិត្យការងាររបស់សាកល-វិទ្យាល័យ ក្នុងករណី ដែលយល់ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និង បែបបទ ដែលមានចែងក្នុងច្បាប់ និង បទប្បញ្ញត្តិ ដែលមានជាធរមាន ។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៧..**

**២៧.១..** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ជ.គ** ត្រូវធ្វើរបាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានរយៈពេល ១ (មួយ) ខែ គិតចាប់ថ្ងៃទទួលឯកសារ ដើម្បីផ្ដល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាន ពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដែលបញ្ជូនមកដោយសាកលវិទ្យាធិការ នៃ **ស.ជ.គ** ដើម្បីផ្ដល់ ការយល់ព្រមលើឯកសារទាំងនេះ ។

**២៧.២..** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តំណាងត្រូវផ្ញើទៅសាកលវិទ្យាធិការ នៃ **ស.ជ.គ** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ សាកលវិទ្យាធិការ នៃ**ស.ជ.គ** ត្រូវជូនពត៌មាននេះដល់ក្រុមប្រឹក្សាភិបាល យ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ត្រូវបានលើកឡើង ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា ២៨..**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការ **ស.ជ.គ** ដូចរៀបរាប់ខាងក្រោម ត្រូវដាក់សុំការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមការផ្តល់យោបល់ ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលក់ ឬ ផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ នៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ២៩..**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ **ស.ជ.គ** ។ មន្ត្រីនេះ មានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និង ជាក្រោយលើ **ស.ជ.គ** ស្របតាមអនុក្រឹត្យលេខ៨១ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា តាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និង តាមអង្គភាពសាធារណៈ ដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣០..**

**៣០.១..** ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ នៃ **ស.ជ.គ** ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.២.. ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគណនេយ្យកណ្តាល នៃរតនាគារជាតិ និង ក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០.៣.. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួតពិនិត្យ លើសាកលវិទ្យាល័យ នៅពេលដែលយល់ថាចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣១..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣២

-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៤៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យលេខ ៤២ អនក្រ.បក

## ស្តីពី

## ការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**មាត្រា មួយ.-** មាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យលេខ ៤២អនក្រ.បក ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ៣ ថ្មី.-** អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិក ក្រុមប្រឹក្សាធម្មនុញ្ញដែលមានវត្តមាន ។ អគ្គលេខាធិការ និងអគ្គលេខាធិការរងមានឋានៈស្មើនឹងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។

**មាត្រា ៤ ថ្មី.-** អគ្គលេខាធិការដ្ឋាន មានអគ្គនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលមួយចំនួននិងនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលមួយចំនួនសម្រាប់ជួយការងារ ។ នាយកដ្ឋានចែកជាការិយាល័យ ។ នៅក្នុងកម្រិតឥណទាន ដែលបើកឱ្យចាយសម្រាប់ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើស តែងតាំងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន តាមសំណើរបស់អគ្គលេខាធិការ ។ បុគ្គលិកទាំងអស់អាចជ្រើសរើសថ្មី ឬផ្ទេរពីស្ថាប័នរដ្ឋផ្សេងៗទៀតក៏បាន ។ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញមានប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតស្មើនឹងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

**មាត្រា ពីរ.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការ រាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និង មាត្រា២

-រាជកិច្ច ✓

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៣៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ប្រគេន ព្រះតេជគុណ **អ៊ុំ គឹមអាន** គ្រូសូត្រវត្តរស្មីសោភណារាម ដែលមានស្នាព្រះហស្តល្អ ក្នុងការចូលរួមដឹកនាំកសាង វត្តរស្មីសោភណារាម ស្ថិតនៅឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល អោយមានការរីកចំរើនជាលំដាប់ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✕

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

A.02

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ នៅ វត្តរស្មីសោភណារាម ឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោកស្រី **សូ សុគន្ធា** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.៧០០ ដុល្លារ |
| ២-លោក **អ៊ុក ម៉ុណ្ណា** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ៣-លោក **ម៉ែន ផាត** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ១០.១០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-អ្នកស្រី **ជា នឹម** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ២-អ្នកស្រី **អ៊ឹម ថុល** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ៣-លោកស្រី **ឆាយ យ៉េន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ៤-លោកស្រី **អ៊ុក ឥណ្ណា** | សប្បុរសជននៅក្រុងភ្នំពេញ | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ៥-លោកស្រី **អ៊ុំ ជឹម** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.០៥០ ដុល្លារ |

៦-លោក **មាន សាវ៉ាត** សប្បុរសជននៅខេត្តកណ្ដាល ថវិកាចំនួន ៥.០៥០ ដុល្លារ
៧-លោក **មាស នួច** គ្រូសាលាពុទ្ធិកសិក្សាវត្តរស្មីសោភណារាម ថវិកាចំនួន ៥.០៣០ ដុល្លារ
៨-លោក **អ៊ុំ សាមុត** សប្បុរសជននៅខេត្តកណ្ដាល ថវិកាចំនួន ៥.០៣០ ដុល្លារ

**គ.មេដាយសេរីវឌ្ឍនៈខ្លាបនាជាតិ :**

១-លោក **យឹម អាន** សប្បុរសជននៅខេត្តកណ្ដាល ថវិកាចំនួន ១.៣៨០ ដុល្លារ
២-ឧបាសិកា **ម៉ុក សុខន** សប្បុរសជននៅខេត្តកណ្ដាល ថវិកាចំនួន ១.៣០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ៣ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

A.04

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី នៃ *អង្គការមិត្តសំឡាញ់* ចំនួន ០៦រូប ដែលបានធ្វើសហប្រតិបត្តិការ ជួយស្តារ និង អភិវឌ្ឍន៍ វិស័យសង្គមកិច្ច នៅកម្ពុជា ពិសេសលើកម្មវិធីក្មេងអនាថា តាំងពីឆ្នាំ ១៩៩៤ រហូតដល់បច្ចុប្បន្ន ចំណាយអស់ថវិកាជាច្រើនលានដុល្លារ ដូចមានរាយនាមខាងក្រោម :-

**ក. មេដាយមាសស្ថាបនាជាតិ :**

១-លោក SEBASTIEN MAROT អ្នកសំរបសំរួលអង្គការមិត្តសំឡាញ់

២-លោកស្រី **លី សុផាត** នាយិកា កម្មវិធី

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ម៉ាន ផល្លី** ប្រធានកម្មវិធី បំណិនជីវិត

២-លោកស្រី **អ៊ឹម ស្រីពៅ** ប្រធានកម្មវិធី សមាហរណកម្ម

៣-លោកស្រី **ឡុង ស៊ីថន** អ្នកគ្រូបង្រៀន

៤-លោកស្រី **អ៊ុំ មាស** អ្នកឧបត្ថម្ភ អាហារ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

A.10-11

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ចំនួន ០១គ្រឿង ជូន លោក *Udo ter Meulen* សាស្ត្រាចារ្យ នៅសាកលវិទ្យាល័យ *Gottingen* នៃប្រទេសអាល្លឺម៉ង់ ដែលបានធ្វើសហប្រតិបត្តិការយ៉ាងល្អ ជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងការជួយអភិវឌ្ឍន៍ " មហាវិទ្យាល័យវិទ្យាសាស្ត្រ និង វេជ្ជសាស្ត្រសត្វ " ដោយចំណាយថវិកាជំនួយ អស់ចំនួន ១០០.០០០ *DM* និង ៥០.០០០ *USD* ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.90

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ចៀក ម៉ឺន** សមាជិកក្រុមប្រឹក្សាឃុំពោធិបាន ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន អស់ចំនួន ១៥.៨០០ ដុល្លារ សំរាប់ជួយកសាងស្ពានមួយកន្លែង បណ្តោយ ១៥.៥០ ម៉ែត្រ ទទឹង ៣.៥០ម៉ែត្រ ធ្វើពីបេតុង ស្ថិតនៅ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

A.15

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស / រកម / ០៦៩៦ / ០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ស ម្រេ ច

**មាត្រា ១ :** តែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ឯក ចណ្ណី | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២- ឯកឧត្តម | ហង់ជួន ណារ៉ុន | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម | ជា វ៉ាន់ដេត | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៤- វរសេនីយ៍ឯក | **ហ៊ុំ ចំរុងដារ៉ា** | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥- លោក | **ឈួច ហោខ** | អគ្គនាយកទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៦- តំណាងនិយោជិត | | ទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៧- ឧកញ៉ា | **លីម មុំនស្ធរ** | តំណាងសភាពាណិជ្ជកម្ម | សមាជិក |

**មាត្រា ២:** សមាសភាពក្រុមប្រឹក្សាភិបាល ដូចមានចែងក្នុងមាត្រា ១ ត្រូវបានតែងតាំងសម្រាប់រយៈពេល ៣ (បី) ឆ្នាំ។ អាណត្តិនេះ អាចបន្តជាថ្មីទៀតបាន។

**មាត្រា ៣:** មុខងាររបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ចប់បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ដែលបានពិភាក្សាសម្រេចលើគណនី នៃការិយបរិច្ឆេទទី ៣ របស់ទូរគមនាគមន៍កម្ពុជា។ សមាជិកក្រុមប្រឹក្សាភិបាល អាចត្រូវផ្លាស់ប្តូរដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាមី។

**មាត្រា ៤:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ ប្រធានសភាពាណិជ្ជកម្ម និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងមាត្រា ៥*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * ***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **សួន ខុន** ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខា - ប្រមាញ់ និង នេសាទ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា - ប្រមាញ់ និង នេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * ***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ០៣ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៦៦ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន លោកស្រី **យស់ ម៉ារាណា** បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ: ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន លោក **សំ ឌន** បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧៥ ...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន លោក **កាន់ ផារិទ្ធ** បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ - ខែ មីនា . ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន លោកស្រី ផាន់ ឡូទី បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០១ . ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការតម្លើងឋានៈមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន លោក សូ សីថា បច្ចុប្បន្នទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេស អូស្ត្រាលី និងនូវែលហ្សេឡង់ ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេស អូស្ត្រាលី និង នូវែលហ្សេឡង់ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...២៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១:** ត្រូវបានតែងតាំង លោក **កែច តគ្គី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ជាអគ្គទីប្រឹក្សាស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ស៊ឹម ស៊ី** សប្បុរសជនខ្មែរ រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយជីកស្តារស្រះទឹក ចំនួន ០៤ នៅតាមបណ្តាវត្ត នៃស្រុកបន្ទាយមាស និង ស្រុកអង្គរជ័យ ខេត្តកំពត ចំណាយអស់ទឹកប្រាក់សរុបចំនួន ១៩.៧២៦,៥០ ដុល្លារ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។ ✕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.141

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

꧁

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **Takanobu KOBAYASHI** ទីប្រឹក្សាបច្ចេកទេស របស់អង្គការ JICA ប្រចាំក្រសួងធនធានទឹក និង ឧតុនិយម ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយអភិវឌ្ឍន៍ វិស័យធនធានទឹក នៅកម្ពុជា រយៈពេល០៣ឆ្នាំ ( ២០០២-២០០៥ ) សំរេចបាននូវសមិទ្ធផលធំៗជាច្រើន ដែលមានតម្លៃជាទឹកប្រាក់ ចំនួន ២៨.២៤៤.០០០ ដុល្លារ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.143

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤២៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៌៌៌

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន និង ក្រុមហ៊ុនជប៉ុន ដែលបានផ្តល់ថវិកាជួយកសាងវិស័យ អប់រំ នៅខេត្តកំពត ដូចមានខាងក្រោម :-

១-លោក ISAO YAKENO ដែលបានផ្តល់ថវិកា ១៦.៦១៥.០២ ដុល្លារ ជួយកសាងអគារសិក្សា និងឧបត្ថម្ភសម្ភារៈសិក្សា បង្គន់អនាម័យ និង ម៉ាស៊ីនបូមទឹក នៅសាលាបឋមសិក្សាក្រាំងស្វាយ ស្រុកឈូក ខេត្តកំពត ។

២-ក្រុមហ៊ុន *ការហ្វេវ៉ូទ័រ* ជប៉ុន បានផ្តល់ថវិកា ៩៩.៤៨៤ ដុល្លារ ជួយកសាងអគារសិក្សា ០៣ខ្នង នៅស្រុកកំពង់ត្រាច និង ស្រុកកំពត ខេត្តកំពត ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៩រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលជាច្រើន រួមចំណែកក្នុងការអភិវឌ្ឍន៍ វិស័យព្រះពុទ្ធសាសនា នៅក្នុងពុទ្ធសីមា វត្តទួលសុវណ្ណារាម សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានចំណាយអស់ថវិកា ចំនួន ១១០.៣១៥ ដុល្លារ និង ៦.៥៥៦.០០០ រៀល ។

២-ឯកឧត្តម ឧត្តមសេនីយ៍ផ្កាយមាសបួន **មាស សុផា** អគ្គមេបញ្ជាការរង កងទ័ពជើងគោក បានចំណាយអស់ថវិកា ចំនួន ១៩.០២៥ ដុល្លារ ។

៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ខៀ សុខ** ថវិកា ចំនួន ៤០.១៣៥ ដុល្លារ

៤-លោកជំទាវ **ឌី ប៊ូរ៉ាស៊ី** សមាជិកព្រឹទ្ធសភា ថវិកា ចំនួន ១៧.៩២៥ ដុល្លារ

៥-ឧបាសិកា **តាន់ ស៊ុំចហុង** ថវិកា ចំនួន ៣៤.២៣៨ ដុល្លារ

៦-លោក **ជា ឧត្តម** ថវិកា ចំនួន ១២.២៥០ ដុល្លារ

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ឡុង ឃួន** ថវិកា ចំនួន ៥.៤៨០ ដុល្លារ

**គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោក **សៅ សុខ** ថវិកា ចំនួន ៣.១៥០ ដុល្លារ

២-លោក **រឃឹម ជឹម** ថវិកា ចំនួន ២.៨១០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
A.9-10 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១** : តែងតាំងលោក **ឈិ សំអុល** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីទី១ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាការឡើងឋានន្តរស័ក្តិ និងថ្នាក់ទៅតាមគោលការណ៍ ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ បប

# សារាចរ

## ស្តីពី

## ការអភិរក្ស និងអភិវឌ្ឍន៍ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ

សត្វផ្សោតទន្លេមេគង្គជាប្រភេទសត្វផ្សោតដ៏កម្រមួយនៅលើពិភពលោកដែលបច្ចុប្បន្នកំពុងប្រឈមមុខ នឹងការគំរាមកំហែង និងឈានទៅរកការវិនាសសាបសូន្យ ប្រសិនបើគ្មានវិធានការការពារ និងអភិរក្សអោយបានទាន់ពេលវេលា និងប្រសិទ្ធភាព ។

យោងលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០០៤ និងឆ្លងតាមកិច្ចពិភាក្សា និងសំណូមពរនានា នៃសិក្ខាសាលាជាតិស្តីពីការអភិរក្ស និងអភិវឌ្ឍន៍ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ នាថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាលចេញបទបញ្ជាដូចខាងក្រោម :

១-ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីចាត់វិធានការយ៉ាងតឹងរឹង ហាមឃាត់ការនេសាទដោយប្រើប្រាស់មងគ្រប់ប្រភេទ ទប់ស្កាត់ចំពោះបទល្មើសនេសាទដោយប្រើឧបករណ៍ឆក់ គ្រឿងផ្ទុះ ក្បូនឫស្សី ក្បូនឈើដែលបាននឹងកំពុងធ្វើសកម្មភាពក្នុងតំបន់ និងឆ្លងកាត់តំបន់ដែលមានសត្វផ្សោតរស់នៅ ចាប់ពីតំបន់កាំពី ខេត្តក្រចេះ ដល់ព្រំដែនកម្ពុជា-ឡាវ ក្នុងខេត្តស្ទឹងត្រែង ។

២-ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវសិក្សា និងណែនាំអំពីបច្ចេកទេសជំនាញនៃការដាក់សំណាញ់គ្របស្នាបចក្រជលយានយន្តដល់ម្ចាស់ជលយានយន្តគ្រប់ប្រភេទអោយអនុវត្ត ។ ព្រមជាមួយនេះត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ពន្ធ័ និងអាជ្ញាធរដែនដីដើម្បីដាក់ផ្លាកសញ្ញាចរាចរផ្លូវទឹក និងធ្វើការណែនាំដល់អ្នកបើកបរកាណូតធំ និងកាណូតលឿនគ្រប់ប្រភេទដែល ធ្វើដំណើរឆ្លងកាត់តំបន់សត្វផ្សោតរស់នៅនេះត្រូវបន្ថយល្បឿន និងសំលេង ព្រមទាំងហាមដាច់ខាតក្នុងការបង្ហូរប្រេងម៉ាស៊ីន និងកាកសំណល់ផ្សេងៗគ្រប់ប្រភេទចូលក្នុងទឹកទន្លេ ដើម្បីការពារបរិស្ថានជាពិសេសក្នុងតំបន់សត្វផ្សោតរស់នៅ ។

៣-ក្រសួងបរិស្ថានសហការជាមួយក្រសួងពាក់ពន្ធ័ និងអាជ្ញាធរដែនដីចាត់វិធានការណែនាំ អប់រំអំពីការថែរក្សាអនាម័យ និងទប់ស្កាត់ជាបន្ទាន់ការបង្ហូរកាកសំណល់នានាចូលទន្លេដែលធ្វើអោយខូចបរិស្ថាន ជាពិសេសក្នុងតំបន់មានសត្វផ្សោតរស់នៅ ។

៤-ក្រសួងទេសចរណ៍ត្រូវយកចិត្តទុកដាក់គិតគូរដល់ការអប់រំបណ្តុះបណ្តាលមគ្គុទេសក៍ទេសចរ គ្រប់គ្រងនិងលើកកំពស់គុណភាពសេវាទេសចរណ៍នៅតំបន់នេះអោយបានល្អ ។

៥-អាជ្ញាធរជាតិទេសចរណ៍ត្រូវសហការជាមួយសមត្ថកិច្ចពាក់ពន្ធ័ទាំងអស់ ដើម្បីធ្វើការឃោសនា អប់រំដល់មហាជនគ្រប់មជ្ឈដ្ឋាន និងប្រជាជននៅតាមសហគមន៍មូលដ្ឋានអោយបានទូលំទូលាយ និងស៊ីជំរៅ ។ ទន្ទឹមនឹងនេះត្រូវសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធរៀបចំចាត់តាំងការិយាល័យពីរកន្លែងនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដើម្បីជាយន្តការអចិន្ត្រៃយ៍ដឹកនាំការងារនេះ និងត្រូវបង្កើតក្រុមល្បាតចល័តជាបន្ទាន់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងឡាយដែលធ្វើអោយវិនាសអន្តរាយដល់ជីវិតសត្វផ្សោត អោយមានប្រសិទ្ធភាព ។

៦-ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួង ស្ថាប័នពាក់ពន្ធ័ អាជ្ញាធរដែនដីនៃខេត្តក្រចេះ និងខេត្តស្ទឹងត្រែងត្រូវបង្កើនការយកចិត្តទុកដាក់ជួយដល់ *អាជ្ញាធរជាតិទេសចរណ៍កម្ពុជា* ក្នុងការអភិរក្សផ្សោតទន្លេមេគង្គ និងអភិវឌ្ឍន៍ទេសចរណ៍ ចាប់ពីតំបន់កាំពីខេត្តក្រចេះរហូតដល់ព្រំដែនកម្ពុជា-ឡាវក្នុងខេត្តស្ទឹងត្រែង ដើម្បីចូលរួមចំណែកក្នុងការ កាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ។

៧-ជនណាដែលប្រព្រឹត្តផ្ទុយពីបទបញ្ជានេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ទទួលបានបទបញ្ជានេះ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួង ស្ថាប័នពាក់ពន្ធ័ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា អភិបាលខេត្តក្រចេះ អភិបាលខេត្តស្ទឹងត្រែង និងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តបទបញ្ជានេះអោយមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៣ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន** :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-សាលាខេត្តក្រចេះ និងខេត្តស្ទឹងត្រែង

-ឯកសារ-កាលប្បវត្តិ

1166

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣១៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៤

# ប្រកាស
## ស្តីពី
## វិធានការជំរុញ និង ប្រមូលបំណុល ចំណូល ថ្លៃឈ្នួលរោងចក្រ សហគ្រាស និង អចលនវត្ថុរបស់រដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស / ៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- យោងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ៣០ប.ប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៧ សរណន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤
- យោងសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩
- យោងកិច្ចសន្យាជួលរោងចក្រ សហគ្រាស និង អចលនវត្ថុ រវាងក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ជាមួយនឹងរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន
- យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១** : ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង (ភាគី " ក " នៃកិច្ចសន្យាជួល រោងចក្រ សហគ្រាស និង អចលនវត្ថុ) ជាអ្នកជំរុញ និង ប្រមូលបំណុល ចំណូលថ្លៃឈ្នួល រោងចក្រ សហគ្រាស និង អចលនវត្ថុ ដែលបានជួលឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលជាភាគី " ខ " នៃកិច្ចសន្យា ។

**ប្រការ២** : ក្រសួង ស្ថាប័ន និង ខេត្ត ក្រុងទាំងអស់ ត្រូវចាត់ចែងឱ្យអ្នកជួលរោងចក្រ សហគ្រាស និង អចលនវត្ថុ អនុវត្តការបង់ប្រាក់ថ្លៃឈ្នួលជូនរដ្ឋដូចតទៅ:

- ត្រូវបង់ត្រង់ទៅថវិការដ្ឋតែម្តងចូលគណនីលេខ : ០២ -៣៥. ១២១១- T០២៣ នៅធនាគារជាតិនៃកម្ពុជា ចំពោះរាល់រោងចក្រ សហគ្រាស និង អចលនវត្ថុដែលមានទីតាំងនៅរាជធានីភ្នំពេញ។ ទន្ទឹមនេះធនាគារជាតិនៃកម្ពុជាត្រូវផ្ញើប្រកាសឥណទាន ឬ បង្កាន់ដៃបង់ប្រាក់ចំនួនបីច្បាប់ ដែលក្នុងនោះមួយច្បាប់ផ្ញើជូន

[illegible] ហិរញ្ញវត្ថុ(នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ ) និង មួយច្បាប់ផ្ញើជូនសាមុក្រសួង ឬ ស្ថាប័នដែលជាភាគី "ក" នៃកិច្ចសន្យា(នាយកដ្ឋាន គណនេយ្យ និង ហិរញ្ញវត្ថុ) ហើយមួយច្បាប់ទៀតផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលបានបង់ប្រាក់ថ្លៃឈ្នួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ ។

-ត្រូវបង់ចូលគណនីថវិការដ្ឋនៅរតនាគារខេត្ត ក្រុងតែម្តង ចំពោះរោងចក្រ សហគ្រាស ឬ អចលនវត្ថុដែលមានទីតាំងនៅតាមខេត្ត ក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញ ។ រតនាគារខេត្ត ក្រុងត្រូវធ្វើសាលាកប័ត្របង់ប្រាក់ចូលថវិការដ្ឋចំនួនបីច្បាប់ ក្នុងនោះមួយច្បាប់ផ្ញើជូនមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មួយច្បាប់ផ្ញើជូនមន្ទីរ ឬ អង្គភាពជំនាញរបស់ក្រសួង ឬ ស្ថាប័ន និង មួយច្បាប់ទៀតផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលបានបង់ប្រាក់ថ្លៃឈ្នួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ ។

ប្រការ៣ :-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ" ជាអ្នកតាមដាន និង កត់ត្រានូវបំណុល ចំណូលថ្លៃឈ្នួល ព្រមទាំងមានវិធានការលើការជំរុញ និង ប្រមូលបំណុល ចំណូលថ្លៃឈ្នួលខាងលើនេះ រួមទាំងធ្វើការណែនាំផ្ទាល់ទៅគ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ឱ្យអនុវត្តតាមកិច្ចសន្យាដែលនៅជាធរមាន ។

-អនុលោមមាត្រា៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១ នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ មាត្រាទី១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និង មាត្រាទី៧ និង ទី១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ប្រសិនបើក្នុងរយៈពេល៣០ថ្ងៃចាប់ពីថ្ងៃដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុណែនាំដល់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ដែលជាភាគី "ក" នៃកិច្ចសន្យាឱ្យមានវិធានការលុបកិច្ចសន្យាប៉ុន្តែនៅតែមិនព្រមមានវិធានការនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងបន្តលើកករណីនោះគោរពជូនសម្តេចនាយករដ្ឋមន្ត្រីដើម្បីចាត់វិធានការជាចុងក្រោយ ។

ប្រការ៤ : រាល់ការស្នើសុំជួល សុំបញ្ចុះថ្លៃឈ្នួល ពន្យាររយៈពេលកិច្ចសន្យាជួល និង សុំរួចថ្លៃឈ្នួលក្នុងរយៈពេលរុះរើជួសជុល និង សាងសង់លើទីតាំងដែលបានជួលពីរដ្ឋ ត្រូវតែអនុវត្តតាមនីតិវិធីនៃបទបញ្ញត្តិស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងបទបញ្ញត្តិ និង នីតិវិធីជាធរមាន ។

ប្រការ៥ : គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ដែលមានជួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ៦ : រាល់ប្រកាស រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អន្តរក្រសួង ស្ថាប័ន ស្តីពីវិធានការប្រមូលចំណូលថ្លៃឈ្នួលអចលនវត្ថុដែលមានន័យផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តជាតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ធនាគារជាតិនៃកម្ពុជា
-ក្រសួង ស្ថាប័ន ពាក់ព័ន្ធ "ដូចប្រការ៥"
-សាលាខេត្ត-ក្រុង ពាក់ព័ន្ធ "ដូចប្រការ៥"
-មន្ទីរ អង្គភាព ពាក់ព័ន្ធ
-រតនាគារខេត្ត-ក្រុង ពាក់ព័ន្ធ
-រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជននៃកិច្ចសន្យា
-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៩៦ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## បែបបទនៃការដោះដូរអចលនទ្រព្យរបស់រដ្ឋ នៅតាមបណ្តាក្រសួង ស្ថាប័ន និង ខេត្ត ក្រុង

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស / ៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

-យោងអនុក្រឹត្យ លេខ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

-យោងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ៣០ប.ប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥

-យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤

-យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ ១** : រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋ "ដីទំនេរ ដី និង អាគាររបស់រដ្ឋ" ត្រូវអនុវត្តតាមដំណើរការឯកជនភាវូបនីយកម្ម របស់គណៈកម្មាធិការឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ។

**ប្រការ ២** : រាល់ការដោះដូរអចលនទ្រព្យរបស់រដ្ឋ "ដីទំនេរ ដី និង អាគាររបស់រដ្ឋ" ត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃជាសាធារណៈ ដោយត្រូវដេញថ្លៃទាំងអចលនទ្រព្យរបស់រដ្ឋ និង សំណង់ថ្មីដែលជាផ្នូររបស់ឯកជន ។

**ប្រការ ៣** : ចំណូលដែលបានមកពីការដេញថ្លៃលក់អចលនទ្រព្យរបស់រដ្ឋ ត្រូវដកល់នៅគណនីឯកជនភាវូបនីយកម្មសំរាប់យកទៅទូទាត់ ថ្លៃសំណង់ថ្មីដែលត្រូវសាងសង់ដោយឯកជន ឬ រួមទាំងថ្លៃទីតាំងដីថ្មីរបស់ឯកជន ។

**ប្រការ ៤ :** ចំណូលដែលបានមកពីការលក់អចលនទ្រព្យរដ្ឋនេះ និង ចំណាយទូទាត់ថ្លៃសំណង់ថ្មីដែលត្រូវផ្តល់ដោយឯកជន ឬ រួមទាំងថ្លៃទីតាំងដីថ្មីរបស់ឯកជន ត្រូវឆ្លុះបញ្ចាំងក្នុងប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋ ស្របតាមបទប្បញ្ញត្តិ និង នីតិវិធីជាធរមាន ។

**ប្រការ ៥ :** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង អាចផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យរបស់រដ្ឋជូនភាគីឯកជនបាន លុះត្រាតែមានការសំរេចជាគោលការណ៍ចុងក្រោយពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បន្ទាប់ពីភាគីឯកជនបានបង់ប្រាក់ថ្លៃទិញអចលនទ្រព្យបានគ្រប់ចំនួនតាមកំណត់ហេតុដេញថ្លៃ ចូលថវិការដ្ឋតាមគណនីលេខ 02-35.1211-T020 នៅធនាគារជាតិនៃកម្ពុជា ព្រមទាំងភាគីឯកជនបានបំពេញកាតព្វកិច្ច ដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងទីតាំងដែលដេញថ្លៃបាននោះរួចរាល់ជាស្ថាពរ ។

**ប្រការ ៦ :** គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ព្រមទាំងនាយកដ្ឋានជំនាញ និង មន្ទីរជំនាញពាក់ព័ន្ធទាំងអស់ ត្រូវសហការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៧ :** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តជាគតិយុត្តិ ចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ តទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៧៤៥ សរណន.កសក

## សារាចរណែនាំ

## ការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពី បមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម

ក្នុងបំណងដ៏ខ្លាំងក្លា ជំរុញការអភិវឌ្ឍវិស័យកសិកម្មដែលជារចនាសម្ព័ន្ធស្នូលនៃខឿនសេដ្ឋកិច្ចជាតិ និងជាអាទិភាពដ៏មានសារៈសំខាន់មួយនៃគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច សំដៅពង្រីកផលិតកម្មកសិកម្ម ធានានូវនិរន្តរភាព សុវត្ថិភាពស្បៀងអាហារ និងធានាផ្គត់ផ្គង់វត្ថុធាតុដើមដល់ឧស្សាហកម្មកែច្នៃ និងបង្កើតការនាំចេញ រាជរដ្ឋាភិបាលបានកំណត់ និងដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តដល់ផលិតកម្មកសិកម្មជាបន្តបន្ទាប់ តាមរយៈការផ្តល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីភោគៈ ដីសម្បទាន ការបើកទូលាយ និងការបន្ធូរបន្ថយពន្ធនាំចេញផលិតផលកសិកម្ម និងការនាំចូលមធ្យោបាយ និងសម្ភារៈផ្សេងៗបំរើឱ្យវិស័យកសិកម្ម។ ទន្ទឹមនឹងនេះដោយពិនិត្យឃើញនូវបាតុភាពអនាធិបតេយ្យក្នុងការផលិត ការនាំចូល ការធ្វើអាជីវកម្ម លក់ដូរសម្ភារៈកសិកម្មក្លែងបន្លំគុណភាព ខ្វះគុណភាព និងថ្នាំកសិកម្មហាមឃាត់ដែលបានបង្កផលប៉ះពាល់ដល់សុខុមាលភាពសង្គម ប៉ះពាល់ដល់បរិស្ថានសង្គម និងធម្មជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម ក្នុងទិសដៅបង្កើតឱ្យមានបមាណី និងយន្តការគ្រប់គ្រងសម្ភារៈកសិកម្មមួយសមស្រប។

ដើម្បីអនុវត្តអនុក្រឹត្យរបស់រាជរដ្ឋាភិបាលខាងលើនេះឱ្យបានប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលជាវិជ្ជមានក្នុងការបំបាត់ ឬកាត់បន្ថយបាតុភាពអនាធិបតេយ្យខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំអនុវត្តដូចតទៅ :

### I. ការធ្វើអាជីវកម្មសម្ភារៈកសិកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបាននិងកំពុងមានបំណងផលិត កែច្នៃ ស្តុក ផ្គត់ផ្គង់ វេចខ្ចប់ជាថ្មី នាំចេញ នាំចូល លក់ដុំ លក់រាយសម្ភារៈកសិកម្ម រួមមានថ្នាំកសិកម្ម ជីគីមី គ្រាប់ពូជ បំណែកពូជដំណាំ បសុឱសថ ចំណីសត្វ និងចំណីបន្ថែម ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**I.១ ការដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម**

ក- សម្រាប់ការធ្វើអាជីវកម្ម ផលិត កែច្នៃ ស្តុក ផ្គត់ផ្គង់ វេចខ្ចប់ជាថ្មី នាំចេញ និងនាំចូលសម្ភារៈកសិកម្ម រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ " នាយកដ្ឋាននីតិកម្មកសិកម្ម " តាមបែបបទដូចខាងក្រោម :

១- ពាក្យសុំមានបិទតែម ( មានគំរូ) ចំនួន ២ ច្បាប់

២- ប្រវត្តិរូបសង្ខេបរបស់អាជីវករមានបិទរូបថត ៤x៦ មានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៣- អត្តសញ្ញាណប័ណ្ណថតចម្លង ចំនួន ២ ច្បាប់

៤- កិច្ចសន្យានៃការធ្វើអាជីវកម្ម ( មានគំរូ ) ចំនួន ២ ច្បាប់

៥- លិខិតបញ្ជាក់ពីទីតាំងធ្វើអាជីវកម្មចេញដោយរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៦- លិខិតអនុញ្ញាតឱ្យដាក់ទីតាំងស្តុកចេញដោយក្រសួងបរិស្ថាន( សម្រាប់ថ្នាំកសិកម្ម ) ចំនួន ២ ច្បាប់

៧- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម ចំនួន ២ ច្បាប់

ខ- សម្រាប់ការធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារៈកសិកម្ម រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង តាមបែបបទដូចខាងក្រោម :

១- ពាក្យសុំមានបិទតែម ( មានគំរូ ) ចំនួន ២ ច្បាប់

២- ប្រវត្តិរូបសង្ខេបរបស់អាជីវករមានបិទរូបថត ៤ x ៦ មានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ ចំនួន ២ ច្បាប់

៣- អត្តសញ្ញាណប័ណ្ណថតចម្លង ចំនួន ២ ច្បាប់

៤- កិច្ចសន្យានៃការធ្វើអាជីវកម្ម ( មានគំរូ ) ចំនួន ២ ច្បាប់

៥- លិខិតអនុញ្ញាតដាក់ទីតាំងស្តុក ចេញដោយមន្ទីរបរិស្ថានខេត្ត ក្រុង ( សម្រាប់តែថ្នាំកសិកម្ម ) ។ ចំនួន ២ ច្បាប់

**I.២ សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម**

ក- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬបដិសេធពាក្យសុំធ្វើអាជីវកម្ម ផលិត កែច្នៃ ស្តុក ផ្គត់ផ្គង់ និងវេចខ្ចប់ជាថ្មី នាំចេញ នាំចូលសម្ភារៈកសិកម្ម សម្រាប់ធ្វើពាណិជ្ជកម្ម ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលក្រសួងបានទទួលសំណុំលិខិតជាផ្លូវការគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ខ- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង នឹងត្រូវផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬបដិសេធពាក្យសុំធ្វើអាជីវកម្មដល់អាជីវករលក់ដុំ លក់រាយសម្ភារៈកសិកម្មក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង បានទទួលសំណុំលិខិតជាផ្លូវការ គ្រប់គ្រាន់ និងត្រឹមត្រូវ។

## II. ការចុះបញ្ជិកាសម្ភារៈកសិកម្ម

ប្រភេទសម្ភារៈកសិកម្មដែលរួមមាន ថ្នាំកសិកម្ម ជីគីមី គ្រាប់ពូជមានវិញ្ញាបនបត្រ បំណែកពូជដំណាំ ចំណីសត្វ ឬចំណីបន្ថែម អាចអនុញ្ញាតឱ្យផលិត នាំចូលសម្រាប់ធ្វើពាណិជ្ជកម្ម លក់ដូរ និងប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែសម្ភារៈកសិកម្មទាំងនោះបានចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ ។

ប្រភេទសម្ភារៈកសិកម្មដែលមានរូបមន្ត ឬឈ្មោះពាណិជ្ជកម្មខុសគ្នា ត្រូវធ្វើការចុះបញ្ជិកាផ្សេងគ្នា។ រូបវន្តបុគ្គល ឬនីតិបុគ្គល មានបំណងផលិតគ្រាប់ពូជមានវិញ្ញាបនបត្រ ឬបំណែកពូជដំណាំដែលបានចុះបញ្ជិកាហើយដើម្បីធ្វើពាណិជ្ជកម្ម ត្រូវអនុវត្តតាមបច្ចេកវិទ្យាដែលបានណែនាំសម្រាប់ការផលិត និងដំណើរការរៀបចំទុកដាក់គ្រាប់ពូជទាំងនោះ ។

### II.១ ការដាក់ពាក្យសុំចុះបញ្ជិកាសម្ភារៈកសិកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំធ្វើការចុះបញ្ជិកាសម្ភារៈកសិកម្មនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ " នាយកដ្ឋាននីតិកម្មកសិកម្ម " តាមបែបបទដូចខាងក្រោម :

| | |
|---|---|
| ១- ពាក្យសុំចុះបញ្ជិកា ( មានគំរូ ) | ចំនួន ២ ច្បាប់ |
| ២- លិខិតថតចម្លងការអនុញ្ញាតធ្វើអាជីវកម្ម ( បើសិនជាមាន) | ចំនួន ២ ច្បាប់ |
| ៣- ពតិមានបច្ចេកទេសស្តីពីផលិតផល ជាភាសាខ្មែរ និងអង់គ្លេស | ចំនួន ២ ច្បាប់ |
| ៤- ការធានាគុណភាព ឬវិញ្ញាបនបត្របញ្ជាក់គុណភាពពីរោងចក្រផលិត | ចំនួន ២ ច្បាប់ |
| ៥- គំរូសម្ភារៈវេចខ្ចប់ និងស្លាកសញ្ញាជាអក្សរខ្មែរ | ចំនួន ២ សន្លឹក |
| ៦- គំរូសំណាកនៃផលិតផល ដើម្បីវិភាគ ឬសិក្សាពិសោធន៍ | ចំនួន២ ឯកតា |

### II.២ សមត្ថកិច្ចក្នុងការផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម

ក-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម ដែលសមស្របសម្រាប់លក់ដូរ និងប្រើប្រាស់ ជូនរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលសំណុំលិខិតជាផ្លូវការគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ខ-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានសិទ្ធិដាច់ខាតមិនធ្វើការចុះបញ្ជិកានូវផលិតផលសម្ភារៈកសិកម្មណាដែលពិនិត្យឃើញថា :

- អាចមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន
- ស្ថិតក្នុងបញ្ជីហាមប្រើប្រាស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខូចគុណភាព ឬក្លែងបន្លំគុណភាព ប្រភេទ ឬបរិមាណធាតុសកម្មខុសពីប្រភេទ ឬបរិមាណធាតុសកម្ម

បញ្ជាក់លើស្លាកសញ្ញា ឬឯកសារបច្ចេកទេស

- ពុំមានការវេចខ្ចប់ត្រឹមត្រូវ និងមានស្លាកសញ្ញា និងពត៌មានបច្ចេកទេសច្បាស់លាស់ជាភាសាខ្មែរ សមស្របតាមគោលការណ៍ដែលក្រសួងបានកំណត់
- គ្មានប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការប្រើប្រាស់ ឬគ្មានផលប្រយោជន៍ដល់កសិករ
- ជាប្រភេទគ្រាប់ពូជដែលធ្វើការបំរែបំរួលសែន (GMO)
- ជាផលិតផលនាំចូលដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## II.៣ បញ្ជិកាថ្នាំកសិកម្ម

ចំពោះថ្នាំកសិកម្មដែលជាប្រភេទសម្ភារៈកសិកម្មអាចបង្កគ្រោះថ្នាក់ និងមានផលប៉ះពាល់ខ្លាំងជាងគេដល់សុខភាពមនុស្ស សត្វ បរិស្ថានសង្គម និងធម្មជាតិ គឺមានបែបបទ និងលក្ខខណ្ឌនៃការចុះបញ្ជិកាដោយឡែកដូចខាងក្រោម :

១- បញ្ជិកាបណ្តោះអាសន្ន : បញ្ជិកានេះត្រូវធ្វើចំពោះគ្រប់មុខថ្នាំកសិកម្មណាដែលមានចែងក្នុងប្រកាសអនុញ្ញាតឱ្យប្រើប្រាស់ជាបណ្តោះអាសន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយដែលកំពុងត្រូវបានចរាចរលក់នៅតាមទីផ្សារ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់បញ្ជិកាបណ្តោះអាសន្ន ដែលមានសុពលភាពរយៈពេល០១ឆ្នាំ ប្រសិនបើថ្នាំកសិកម្មនោះមានឯកសារអះអាងអំពីប្រសិទ្ធភាព និងសុវត្ថិភាពគ្រប់គ្រាន់ និងត្រឹមត្រូវ។ បញ្ជិកានេះនឹងត្រូវបានផ្ទេរទៅជាបញ្ជិកាពេញលេញ ក្នុងរយៈពេលមួយឆ្នាំក្រោយ ប្រសិនបើអ្នកស្នើសុំចុះបញ្ជិកាបានបំពេញនូវគ្រប់តម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការសុំពន្យាសម្រាប់រយៈពេលមួយឆ្នាំអាចអនុញ្ញាតបានក្នុងករណីដែលមានមូលហេតុសមស្រប ។

ក្រោយពីទទួលបានបញ្ជិកាបណ្តោះអាសន្នហើយ ម្ចាស់ផលិតផលថ្នាំកសិកម្មនោះអាចស្នើសុំនាំចូល ឬផលិតក្នុងបរិមាណកំណត់មួយ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងសិក្សាទីផ្សារ។

២- បញ្ជិកាសិតក្នុងលក្ខខណ្ឌ : បញ្ជិកានេះត្រូវធ្វើចំពោះថ្នាំកសិកម្មណា ដែលត្រូវបានស្នើសុំចុះបញ្ជិកាលើកដំបូង តែត្រូវផ្តល់បន្ថែមនូវទិន្នន័យ ឬលក្ខខណ្ឌចាំបាច់ដទៃទៀតតាមតម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បញ្ជិកានេះនឹងត្រូវបានផ្ទេរទៅជាបញ្ជិកាពេញលេញក្នុងរយៈពេលមួយឆ្នាំក្រោយ ប្រសិនបើអ្នកស្នើសុំចុះបញ្ជិកាបានបំពេញនូវគ្រប់តម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការសុំពន្យាសម្រាប់រយៈពេលមួយឆ្នាំអាចអនុញ្ញាតបានក្នុងករណីដែលមានមូលហេតុសមស្រប ។

៣-<u>បញ្ជិកាពេញលេញ</u> : បញ្ជិកានេះត្រូវធ្វើចំពោះថ្នាំកសិកម្មណា ដែលអ្នកសុំចុះបញ្ជិកាបានបំពេញនូវគ្រប់តម្រូវការបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

វិញ្ញាបនបត្រចុះបញ្ជិកាព្រមទាំងលេខបញ្ជិកានឹងត្រូវចេញជូនដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្នុងករណីដែលគ្មានការដកហូត ឬលុបចោលណាមួយនោះ វិញ្ញាបនបត្រចុះបញ្ជិកាពេញលេញមានសុពលភាពរយៈពេល០៣ឆ្នាំ ។ ការចុះបញ្ជិកាជាថ្មីអាចនឹងទទួលបានក្រោយពីក្រសួងបានទទួលនូវពាក្យស្នើសុំ និងទិន្នន័យបន្ថែម។ ការខកខានក្នុងការសុំចុះបញ្ជិកាជាថ្មី ពេលសុពលភាពត្រូវបានបញ្ចប់ មុខថ្នាំកសិកម្មនោះពុំអាចធ្វើការនាំចូល និងធ្វើចរាចរលក់ដូរបានឡើយ ។

ក្នុងរយៈពេលបីខែយ៉ាងយូរមុនផុតកំណត់សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជិកាពេញលេញ សាមីជន ឬក្រុមហ៊ុន ម្ចាស់ផលិតផល ត្រូវបំពេញសំណុំលិខិតចុះបញ្ជិកាជាថ្មីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ " នាយកដ្ឋាននីតិកម្មកសិកម្ម " ដូចខាងក្រោម :

- ពាក្យសុំចុះបញ្ជិកាជាថ្មី ( មានគំរូ ) ចំនួន ២ ច្បាប់
- គំរូសំណាកនៃផលិតផលដើម្បីធ្វើការវិភាគ ចំនួន ២ ច្បាប់
- វិញ្ញាបនបត្របញ្ជិកាចាស់ ចំនួន ១ ច្បាប់

៤-<u>ការអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ពិសោធន៍</u> : គឺជាការអនុញ្ញាត ដើម្បីនាំចូលថ្នាំកសិកម្មណាដែលមិនទាន់បានចុះបញ្ជិកា សម្រាប់យកមកប្រើប្រាស់ក្នុងគោលបំណងសិក្សាស្រាវជ្រាវប៉ុណ្ណោះ ។

## III. ការនាំចេញ នាំចូលសម្ភារៈកសិកម្ម

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចទទួលបាននូវលិខិតអនុញ្ញាតឱ្យធ្វើការនាំចូល ឬនាំចេញនូវមុខសម្ភារៈណាមួយនោះ លុះណាតែរូបវន្តបុគ្គល ឬនីតិបុគ្គលនោះបានទទួលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ហើយមុខសម្ភារៈកសិកម្មដែលស្នើសុំនាំចូល ឬនាំចេញនោះ ត្រូវបានទទួលឱ្យចុះបញ្ជិកា និងទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាត្រឹមត្រូវជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### III.១ ការដាក់ពាក្យសុំលិខិតអនុញ្ញាតនាំចេញ នាំចូលសម្ភារៈកសិកម្ម

១/សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតឱ្យនាំចូលមាន :

- ពាក្យសុំ ( មានគំរូ ) ចំនួន ២ ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មថតចម្លង ចំនួន ២ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជិកាថតចម្លង ចំនួន ២ ច្បាប់
- វិញ្ញាបនបត្រអនាម័យផលិតផលចេញដោយប្រទេសនាំចេញ ចំនួន ២ ច្បាប់

២/សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតនាំចេញមាន :

- ពាក្យសុំ ( មានគំរូ ) ចំនួន ២ ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មថតចម្លង ចំនួន ២ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីកាថតចម្លង ចំនួន ២ ច្បាប់

### III.២ សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់នូវសេចក្តីសម្រេចរបស់ខ្លួន ចំពោះការផ្តល់ ឬមិនផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានសំណុំលិខិតគ្រប់គ្រាន់ និងត្រឹមត្រូវជាផ្លូវការពីអ្នកស្នើសុំ ។

បរិមាណនៃថ្នាំកសិកម្មដែលអាចអនុញ្ញាតឱ្យធ្វើការនាំចូល ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើលក្ខខណ្ឌទុកដាក់ លទ្ធភាពឃ្លាំងស្តុករបស់អ្នកស្នើសុំ តម្រូវការក្នុងស្រុក និងដើម្បីចៀសវាងផលប៉ះពាល់ដល់បរិស្ថាននៅពេលត្រូវការកម្ទេចចោលនូវថ្នាំកសិកម្មដែលផុតកំណត់ការប្រើប្រាស់ ។

ការនាំចេញ នាំចូលនូវគ្រាប់ពូជ និង បំណែកពូជដំណាំ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

លិខិតអនុញ្ញាតនាំចេញ នាំចូលមានសុពលភាពរយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃដែលចេញលិខិតអនុញ្ញាតនោះ ។

## IV.ការដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីកាសម្ភារៈកសិកម្ម

### IV.១ ការដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារៈកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្មក្នុងករណី :

- អ្នកកាន់លិខិតអនុញ្ញាតមិនគោរពតាមកិច្ចសន្យានៃការធ្វើអាជីវកម្មរបស់ខ្លួន ឬបានបំពានលើសារាចរណែនាំនេះ ឬបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យ ស្តីពីបមាណីនិងការគ្រប់គ្រងសម្ភារៈកសិកម្ម
- ទីតាំងគ្រឹះស្ថានធ្វើអាជីវកម្មមានការផ្លាស់ប្តូរ ហើយមិនបានជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន ឬយ៉ាងយូរ១០ ថ្ងៃក្រោយពីការផ្លាស់ប្តូរ ។

### IV.២ ការដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជិកាសម្ភារៈកសិកម្មក្នុងករណី :

- លទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញពីផលប៉ះពាល់ធ្ងន់ធ្ងរជាយថាហេតុដល់សុខភាពមនុស្ស សត្វ បរិស្ថាន បណ្ដាលមកពីឥទ្ធិពលនៃការប្រើប្រាស់មុខសម្ភារៈកសិកម្មនោះរយៈពេលយូរឆ្នាំ
- មុខសម្ភារៈកសិកម្មដែលបានផលិត នាំចូល និងធ្វើអាជីវកម្មលក់ដូរខុសពីសម្ភារៈកសិកម្មដែលបានចុះបញ្ជិកា ទាំងគុណភាព ការវេចខ្ចប់ ស្លាកសញ្ញា ។ល។
- អ្នកកាន់វិញ្ញាបនបត្រចុះបញ្ជិកាមិនបានគោរពតាមកិច្ចសន្យានៃការធ្វើអាជីវកម្មរបស់ខ្លួន ឬបានបំពានលើសារាចរណែនាំនេះ ឬបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យលេខ៦៩ អនក្រ.បក ស្ដីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម ។

### IV.៣ ការតវ៉ា

អាជីវករមានសិទ្ធិតវ៉ាមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះសេចក្ដីសម្រេចនៃការដកហូត ឬលុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬ វិញ្ញាបនបត្រចុះបញ្ជិកា ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីសម្រេច ។

## V. ការវេចខ្ចប់ និងស្លាកសញ្ញា

### V.១ ថ្នាំកសិកម្ម

- សម្ភារៈវេចខ្ចប់ថ្នាំកសិកម្ម ត្រូវឆ្លើយតបទៅនឹងបមាណីអន្តរជាតិ មានភាពជាប់មាំ ធានាបានចំពោះរាល់ការលើកដាក់ កាន់យូរ ទុកដាក់ មានលក្ខណៈអាចការពារការចុះអន់គុណភាព ការស្រកមាឌ ការប្ដូរទម្ងន់ ឬក៏ការខូចខាតដទៃទៀត
- ការវេចខ្ចប់ជាថ្មី ឬការផ្ទេរថ្នាំកសិកម្មពីសម្ភារៈវេចខ្ចប់ដើមទៅក្នុងសម្ភារៈវេចខ្ចប់ថ្មីត្រូវហាមឃាត់ ។ ក្នុងករណីចាំបាច់ ការវេចខ្ចប់ជាថ្មី ឬការផ្ទេរថ្នាំកសិកម្ម ពីសម្ភារៈវេចខ្ចប់ដើមទៅក្នុងសម្ភារៈវេចខ្ចប់ថ្មីនេះអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - ១- សម្ភារៈវេចខ្ចប់ជាថ្មី ដែលបានការអនុញ្ញាតរួចហើយនោះ ត្រូវឆ្លើយតបតាមបមាណីនៃការវេចខ្ចប់ ដូចមានចែងក្នុងចំណុច V.១ កថាខ័ណ្ឌ១ នៃសារាចរណែនាំនេះ ។
  - ២- ថ្នាំកសិកម្មដែលត្រូវវេចខ្ចប់ជាថ្មីនោះ បានចុះបញ្ជិការួចហើយនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- ការផ្ទេរ ឬវែលកថ្នាំកសិកម្មណាមួយ ទៅក្នុងសម្ភារៈវេចខ្ចប់ចំណីអាហារ ឬភេសជ្ជៈ ត្រូវហាមឃាត់

- ស្លាកសញ្ញាសម្ភារៈវេចខ្ចប់ថ្នាំកសិកម្ម ត្រូវបិទភ្ជាប់ឱ្យជាប់ល្អ ឬវាយពុម្ពពីលើ នូវស្លាកសញ្ញាជាអក្សរខ្មែរ ងាយយល់ សមស្របតាមលក្ខខណ្ឌកំណត់ដូចខាងក្រោម :

១- ឈ្មោះទូទៅ និងឈ្មោះពាណិជ្ជកម្មថ្នាំកសិកម្ម ( Product Name ) ។

២- ប្រភេទថ្នាំកសិកម្ម ( Type of Pesticide ) ។

៣- ឈ្មោះប្រទេសផលិត ( Origin country ) ។

៤- សមាសភាគនៃធាតុសកម្ម ( Active ingredient and its content ) ។

៥- ប្រភេទនៃទម្រង់ផ្សំ ( Type of Formulation ) ។

៦- ទម្ងន់ ឬចំណុះ ( Net content ) ។

៧- លេខឡូត៍ ( Lot number ) ។

៨- ថ្ងៃខែឆ្នាំផលិត និងថ្ងៃខែឆ្នាំផុតកំណត់ការប្រើប្រាស់ ( Manufacturing date and Expiring date ) ។

១០- លេខបញ្ជិកា ( Registration Number ) ។

១១- របៀបប្រើប្រាស់ ( directions for use ) :

- ប្រភេទដំណាំ ដែលត្រូវប្រើប្រាស់ ( Target Crop )
- ប្រភេទកត្តាចង្រៃដែលត្រូវកំចាត់ ( Target insects, diseases, weeds )
- កម្រិតប្រើ ( Dose rates )
- ភាពលាយបានជាមួយថ្នាំ កសិកម្មដទៃទៀត ( Compatibility )
- វិធីសាស្ត្រ និងពេលវេលានៃការប្រើប្រាស់ (Methods and timing of application )
- រយៈពេលរង់ចាំ មុនពេលប្រមូលផល ( Pre-harvest intervals )
- ការណែនាំអំពីការសង្គ្រោះបន្ទាន់ ( First-aid instructions ) ។

១២- សរសេរជាអក្សរធំៗថា " ទុកឱ្យផុតពីដៃក្មេង " ( Keep out of reach of Children ) ។

១៣- របៀបទុកដាក់ ។

១៤- និមិត្តសញ្ញាបង្ហាញគ្រោះថ្នាក់ ( Pictograms ) ។

១៥- ថ្នាំបន្សាប ( Antidote ) ។

- ចំពោះស្លាកសញ្ញានៃសម្ភារៈវេចខ្ចប់ថ្នាំកសិកម្ម ដែលមានចំណុះតិចជាង ៥០០មិល្លីលីត្រ ឬ៥០០ក្រាម ត្រូវភ្ជាប់បន្ថែមបរិយាយប័ណ្ណ ( Leaflet ) ផ្តល់ពត៌មានលំអិតអំពីផលិតផលនោះ ដែលមានលក្ខណៈអាចបិទជាប់នឹងផលិតផល ចងភ្ជាប់នឹងផលិតផល ឬអាចដាក់ដោយឡែកពីផលិតផល

- ពណ៌ និងការបោះពុម្ពអត្ថបទលើស្លាកសញ្ញា :

១- អត្ថបទលើស្លាកសញ្ញា ត្រូវសរសេរដោយប្រើទឹកពណ៌ខ្មៅលើផ្ទៃក្រដាសពណ៌ស ។

២- ពណ៌ក្រហមអាចប្រើសម្រាប់ឃ្លាសំខាន់ៗដូចជា : ចំណងជើង សញ្ញាគ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន។

៣- វ័ន្ត ( Trace )ពណ៌ក្រហម និង សញ្ញាក្បាលខ្មោច ប្រើសំគាល់គ្រោះថ្នាក់ខ្លាំង ពណ៌លឿង និងសញ្ញាខ្វែង ប្រើសំគាល់គ្រោះថ្នាក់មធ្យម និងពណ៌ខៀវ សំគាល់គ្រោះថ្នាក់ខ្សោយ ។

